ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លេខ ៖ .....១៣៦..... អ.ជ.ប.ជ.អ

# សេចក្តីសម្រេចចិត្ត
# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# លើកទី១ ឆ្នាំ២០១៦

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៦ បានដំណើរការរយៈពេលមួយព្រឹកពេញ នាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ និង ដៃគូអភិវឌ្ឍន៍ រួមទាំងសង្គមស៊ីវិល សរុបប្រមាណចំនួន១៤០រូប។

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៦ បានដំណើរការស្របតាមអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយការចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយ ហើយបានសម្រេចចិត្តដូចតទៅ៖

១. បន្តអនុវត្តដោយម៉ឺងម៉ាត់នូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យ ឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍លើកទី៤ឆ្នាំ២០១៥-២០២០ ដែលជាយុទ្ធសាស្ត្រជាតិតែមួយគត់សម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

២. បន្តអនុវត្តគោលនយោបាយប្រាំពីរចំណុចនៃការប្រយុទ្ធនឹងជំងឺអេដស៍ តាមលិខិតលេខ២០៤៨ សជណ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (អ.ជ.ប.ជ.អ) និង ក្រសួងផែនការ បន្តរៀបចំផែនការវិនិយោគសាធារណៈ៣ឆ្នាំរំកិលជាមួយតម្រូវការថវិកាចំណាយ និងពិនិត្យរកលទ្ធភាពធ្វើការសិក្សាអំពីសេណារីយោវិនិយោគ ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ឆ្ពោះទៅលុបបំបាត់ការរីករាលដាលមេរោគអេដស៍ឲ្យបានមុនឆ្នាំ២០៣០។

៤. អ.ជ.ប.ជ.អ និង ក្រសួងផែនការ នឹងរៀបចំបញ្ចប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រដែលមានសមាជិករងផលប៉ះពាល់ពីការផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ទទួលបានប័ណ្ណសមធម៌ និង នីតិវិធីនៃការអនុវត្ត។



អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវ២៧១កែង១៥០ សង្កាត់ទឹកល្អក់II ខណ្ឌទូលគោក រាជធានីភ្នំពេញ
Tel: (855) 23 885 129 • Fax: (855) 23 885 279 • E-mail: info@naa.org.kh • Website: naa.org.kh

៥. អ.ជ.ប.ជ.អ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបន្តជំរុញការរៀបចំ និង វិភាជន៍កញ្ចប់ថវិកាកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ដល់ក្រសួង ស្ថាប័ន អង្គភាពក្រោមឱវាទទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តសកម្មភាពប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និង ចីរភាព។

៦. អ.ជ.ប.ជ.អ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល បន្តពិនិត្យលទ្ធភាពក្នុងការបង្កើនការវិនិយោគថវិកាជាតិក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍។

៧. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបន្តជំរុញការអនុវត្តប្រកាសលេខ០៨៦ ក.ក.ប.វ/ប្រ.ក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការប្រយុទ្ធនឹងអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និង ការបង្ការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ និង ប្រកាសលេខ១៩៤ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីលក្ខខណ្ឌការងារវិជានអនាម័យ និង សន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ផ្នែកសេវាកម្មាន្ត។

៨. គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តសៀមរាប និង ខេត្តបាត់ដំបងនឹងអនុវត្តគម្រោងសាកល្បងដើម្បីសម្រេចគោលដៅ៩០-៩០-៩០។

៩. អ.ជ.ប.ជ.អ ក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន និង ក្រសួងស្ថាប័នពាក់ព័ន្ធ បន្តជំរុញឲ្យបានខ្លាំងក្លា និង ប្រសិទ្ធភាពនូវការអនុវត្តកម្មវិធីបង្ការការប្រើប្រាស់គ្រឿងញៀននិងការចម្លងមេរោគអេដស៍ ជាពិសេសក្នុងចំណោមក្រុមយុវជនទាំងខាងក្នុង និងខាងក្រៅសាលារៀន។

១០. ក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អ.ជ.ប.ជ.អ ត្រូវរៀបចំយន្តការប្រកបដោយប្រសិទ្ធភាព និង ទាន់ពេលនៃការគ្រប់គ្រងបុគ្គលិកកិច្ចសន្យាដែលបម្រើការងារក្នុងគម្រោងមូលនិធិសកល ដើម្បីមានលទ្ធភាពបន្តការងាររបស់ខ្លួនក្នុងបរិការណ៍នៃការបញ្ចប់ការផ្តល់ប្រាក់ខែ (ប្រាក់លើកទឹកចិត្ត) ពីគម្រោងមូលនិធិសកលនៅក្នុងឆ្នាំ២០១៧ និង ២០១៨ ខាងមុខនេះ។

១១. បន្តពង្រឹង និង ជំរុញកិច្ចសហការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និង អ្នកពាក់ព័ន្ធដ៏ទៃទៀតដើម្បីជំរុញយន្តការឆ្លើយតបការងារប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព និង ចីរភាព។

១២. ជំរុញ និង ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធត្រួតពិនិត្យ តាមដាន និង វាយតម្លៃតាមរយៈកិច្ចសហការនៃការផ្តល់របាយការណ៍ជាប្រចាំអំពីការងារប្រយុទ្ធនឹងជំងឺអេដស៍ នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដែលជាសមាជិក អ.ជ.ប.ជ.អ។

១៣. អ.ជ.ប.ជ.អ មានតួនាទីដឹកនាំគ្រប់គ្រង សម្របសម្រួលអនុវត្តនូវការសម្រេចចិត្តនេះឲ្យមានប្រសិទ្ធភាពដើម្បីឆ្ពោះទៅសម្រេចបានជោគជ័យនូវ "គោលដៅ៩០-៩០-៩០៖

១) ៩0% នៃមនុស្សទាំងអស់ដែលមានផ្ទុកមេរោគអេដស៍ បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ។

២) ៩0% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលបានធ្វើ រោគវិនិច្ឆ័យ បានបន្តទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ។

៣) ៩0% នៃមនុស្សទាំងអស់ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ មិនអាចរកឃើញបន្ទុកមេរោគអេដស៍នៅក្នុងខ្លួន" ។

ខេត្តព្រះសីហនុ ថ្ងៃទី0២ ខែមិថុនា ឆ្នាំ២0១៦

អៀង - មុលី